00282711

ការិ/ក: A252

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| ដាក់ទៅ: | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់: | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដែលទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 30 / 01 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fuy

---

## សំណើសុំព័ត៌មានទាក់ទងនឹងអត្តិភាពដ៏មានឥទ្ធិពលនៃទំនាស់ផលប្រយោជន៍នៃអ្នកស៊ើបអង្កេត របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត Stephen Heder

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fu

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") លោក **អៀង សារី** អនុលោមតាមវិធាន ៣៤(១) នៃវិធានផ្ទៃក្នុង (ហៅថា "វិធាន") តទៅនេះសូមដាក់សំណើនេះ ដើម្បីស្វែងរកព័ត៌មានទាក់ទងនឹងសម្បទាខាងសីលធម៌ និង វិជ្ជាជីវៈរបស់បណ្ឌិត Stephen Heder ដើម្បីបំពេញតួនាទីបច្ចុប្បន្ន ឬ តួនាទីអតីតកាលរបស់គាត់ ក្នុងឋានៈជាអ្នកស៊ើបអង្កេតម្នាក់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស") ដោយពិចារណាថា ក.ស.ច.ស ជាស្ថាប័នមួយ*ឯករាជ្យ*នៅក្នុង អ.វ.ត.ក[1] ត្រូវតែអនុវត្តកិច្ចស៊ើបសួររបស់ខ្លួនដោយ*អនាគតិ*[2] ។ សំណើនេះត្រូវបានធ្វើឡើងដោយមានមូលហេតុដូចខាងក្រោម៖

1. មេធាវីការពារក្តីកាលពីពេលថ្មីៗនេះ បានដឹងតាមរយៈសំណើសៀវភៅមួយក្បាល ដែលដាក់កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ ក្រោមចំណងជើង ថា "*អំពើប្រល័យពូជសាសន៍ និង ការប្រល័យជាតិសាសន៍ឯងនៅកម្ពុជា (Genocide and Auto-Genocide in Cambodia)៖ លិទ្ធិកុំម្មុយនីស្តនិយម, ជាតិនិយម និង អំពើមនុស្សឃាត ឆ្នាំ១៩៧៥ ដល់ ១៩៧៨*" អ្នកស៊ើបអង្កេត Stephen Heder បាននិយាយយោងទៅកាន់គុណវុឌ្ឍិរបស់គាត់ ថាបាន "ស្រាវជ្រាវបក្សកុំម្មុយនីស្តកម្ពុជា CPK អស់រយៈពេល ៣០ឆ្នាំ ក្នុងមុខងារជាអ្នកសារព័ត៌មាន, ភ្នាក់ងារស៊ើបការណ៍សំងាត់, អ្នកតស៊ូមតិសិទ្ធិមនុស្ស, ប្រវត្តិវិទូ, មន្ត្រីអង្គការសហប្រជាជាតិ, អ្នកស្រាវជ្រាវផ្នែកច្បាប់ និង ជាអ្នកវិទ្យាសាស្ត្រផ្នែកនយោបាយ" មុនចូលបំរើការងារជាអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រម-ស៊ើបអង្កេត[3] ។ អ្នកស៊ើបអង្កេត Stephen Heder មិនបានផ្តល់ព័ត៌មានបន្ថែមទៀតទេទាក់ទងនឹងថាតើនៅពេលណា ទីកន្លែងណា ហើយ នរណាជ្រើសរើសគាត់ឱ្យចូលបំរើក្នុងមុខនាទីនេះ ។ សន្មតថា អ្នកស៊ើបអង្កេត Stephen Heder បានធ្វើសំណើសៀវភៅបែបនេះមែន ដូចដែលគាត់បានសារភាពអំពីសកម្មភាពផ្ទាល់ខ្លួនពីមុនៗរបស់គាត់ថាជា "មន្ត្រីស៊ើបការណ៍សំងាត់" នោះនឹងពុំ

---

[1] វិធាន ១៤.១ ។

[2] វិធាន ៥៥.ស

[3] តាមរយៈប្រភពសំងាត់ មេធាវីការពារត្រូវបានផ្តល់នូវឯកសារដែលហាក់ដូចជាឯកសារពិតប្រាកដ ផ្ទុះបញ្ជាំងឱ្យឃើញថា អ្នកស៊ើបអង្កេត Stephen Heder កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ បានដាក់សំណើសៀវភៅមួយក្បាល ក្រោមចំណងជើងថា "*អំពើប្រល័យពូជសាសន៍ និង ការប្រល័យជាតិសាសន៍ឯងនៅកម្ពុជា (Genocide and Auto-Genocide in Cambodia)៖ លិទ្ធិកុំម្មុយនីស្តនិយម, ជាតិនិយម និង អំពើមនុស្សឃាត ឆ្នាំ១៩៧៥ ដល់ ១៩៧៨*" អ្នកស៊ើបអង្កេត Stephen Heder បានយោងសម្បទារបស់គាត់ ថាបាន "ស្រាវជ្រាវបក្សកុំម្មុយនីស្តកម្ពុជា CPK អស់រយៈពេល ៣០ឆ្នាំ ក្នុងមុខងារជាអ្នកសារព័ត៌មាន, មន្ត្រីស៊ើបការណ៍សំងាត់, អ្នកតស៊ូមតិសិទ្ធិមនុស្ស, ប្រវត្តិវិទូ, មន្ត្រីអង្គការសហប្រជាជាតិ, អ្នកស្រាវជ្រាវផ្នែកច្បាប់ និង ជាអ្នកវិទ្យាសាស្ត្រផ្នែកនយោបាយ ដែលជាការចាប់កំណើតឡើងវិញនូវវិជ្ជាជីវៈថ្មីបំផុតខ្ញុំ" (គូសបញ្ជាក់បន្ថែម) ។

សួរមានហេតុផលដើម្បីសង្ស័យអំពីភាពត្រឹមត្រូវរបស់វានោះទេ លុះត្រាតែ អ្នកស៊ើបអង្កេត Stephen Heder មានចេតនាបញ្ចេញបញ្ចូល និងប្រឌិតរឿងនេះឡើង ដើម្បីធ្វើឱ្យបានសម្រេចលើសំណើអាជីវកម្មសៀវភៅនេះ ។ ខណៈដែលមានលេចឡើងនូវលទ្ធភាពដែលថា ព័ត៌មានដែលផ្តល់ឱ្យមេធាវីការពារក្តីអាចជាមានសុក្រិតភាពតិចតួច និងដើម្បីជាប្រយោជន៍ដល់ការបង្ហាញពីវិរិយភាពដ៏ត្រឹមត្រូវ មេធាវីការពារពុំមានជម្រើសផ្សេង ក្រៅអំពីធ្វើការស្រាវជ្រាវលើបញ្ហានេះឡើយ ។

2. ក្នុងខណៈជាភ្នាក់ងារស៊ើបការសំងាត់ អ្នកស៊ើបអង្កេត Stephen Heder អាចទទួលការណែនាំពីរដ្ឋាភិបាលបរទេសមួយ ។ ពិចារណាពីសញ្ជាតិរបស់អ្នកស៊ើបអង្កេត Stephen Heder វាទំបងជាថា គាត់ត្រូវបានជួលដោយភ្នាក់ងារកណ្តាលស៊ើបការណ៍សំងាត់របស់សហរដ្ឋអាមេរិក (ហៅថា "CIA") ដែលជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រជូរចត់នៅអាស៊ីអាគ្នេយ៍ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកកាលពីឆ្នាំ១៩៧០ បានទម្លាក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំមកលើប្រទេសកម្ពុជា បណ្តាលឱ្យមនុស្សដ៏ច្រើនក្រាស់ក្រាល ស្លាប់ និង រងរបួសរាប់មិនអស់ និងបង្កឱ្យសង្គមកម្ពុជាមានអស្ថិរភាពយ៉ាងខ្លាំងសម្បើម[4]។ នៅក្នុងកិច្ចស៊ើបសួរប្រឆាំងនឹងលោក **អៀង សារី** និង អ្នកដទៃទៀតចំពោះឧក្រិដ្ឋកម្មដែលត្រូវគេបានចោទថា បានប្រព្រឹត្តនៅក្នុងអំឡុងពេលនោះ ភស្តុតាងពីទំហំនៃការទម្លាក់គ្រាប់បែក និងផលប៉ះពាល់របស់វា មិនទាន់ត្រូវបានគាស់រំលើងនៅឡើយ ។ ជាក់ស្តែង រដ្ឋាភិបាលសហរដ្ឋអាមេរិកបានរក្សាផលប្រយោជន៍យ៉ាងខ្លាំងនៅក្នុងការបង្រួមតួនាទីរបស់ខ្លួនឱ្យនៅតូចបំផុតនៅក្នុងការទម្លាក់គ្រាប់បែកមកលើប្រជាជនកម្ពុជា និងបណ្តាញចារកម្មយ៉ាងធំរបស់ខ្លួននៅក្នុងតំបន់[5] ។ ប្រសិនបើអ្នកស៊ើបអង្កេតម្នាក់ ក្នុងចំណោមអ្នកស៊ើបអង្កេតជាច្រើននាក់ដែលកំពុងបំរើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានផ្តល់តួនាទីជាភ្នាក់ងារស៊ើបការណ៍សំងាត់ ដែលធ្លាប់ទទួល ឬ នៅតែទទួលការបង្គាប់ពីភ្នាក់ងារចារកម្មនៃ

---

4 [redacted]

5 ឧទាហរណ៍ដ៏ល្អមួយទាក់ទងនឹងបញ្ហានេះ គឺប្រតិបត្តិការសិកដ៏ស្មោកគ្រោករបស់សហរដ្ឋអាមេរិកឈ្មោះ *Operation Menu* ដែលជាប្រតិបត្តការសិកលាក់កំបាំងដ៏ល្បីល្បាញមួយរបស់ទីបញ្ជាការយុទ្ធសាស្ត្រផ្លូវអាកាសរបស់សហរដ្ឋអាមេរិក (U.S. *Strategic Air Command* (SAC) ដែលភាគបូព៌ានៃប្រទេសកម្ពុជាទទួលរងនូវការទម្លាក់គ្រាប់បែកយ៉ាងដំណំ ចាប់ពីខែមីនា ឆ្នាំ១៩៦៩ ដល់ ខែឧសភា ឆ្នាំ១៩៧០ ក្នុងអំឡុងពេលសង្គ្រាមវៀតណាម ។

រដ្ឋាភិបាលបរទេស ការណ៍នេះពិតជាប៉ះពាល់ដល់ភាពឯករាជ្យ និង អនាគតិរបស់អ្នកស៊ើបអង្កេតម្នាក់នោះនៅក្នុងកិច្ចស៊ើបសួរជាពុំខានឡើយ[6] ។

3. ដោយសារតែទំហំ និង ភាពស្មុគស្មាញនៃកិច្ចស៊ើបសួរ ហើយដោយសារតែអ្នកស៊ើបអង្កេត Stephen Heder មិនមែនជាសហចៅក្រមស៊ើបអង្កេត (ហៅថា "ស.ច.ស") គាត់ត្រូវបានប្រគល់នូវមុខងារស៊ើបសួរមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត តាមរយៈយន្តការរបស់ដីកាចាត់ឱ្យស៊ើបសួរជំនួស[7] ។ ជាលទ្ធផល គាត់បានសម្ភាសន៏សាក្សីជាច្រើននាក់ជំនួសអោយសហចៅក្រម-ស៊ើបអង្កេត ព្រមទាំងពង្រាងរបាយការណ៏ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស បានផ្តល់អនុសាសន៏ដោយផ្ទាល់អំពីសាក្សីដែលបានសម្ភាសន៏[8] ។ គេអាចទាញហេតុផលចេញពីតួនាទីនេះបានថា គាត់មិនត្រឹមតែបានផ្តល់មតិយោបល់ដល់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណឹងទេ តែថែមទាំងបានអនុវត្តមុខងាររបស់សហចៅក្រមស៊ើបអង្កេតទៀតផង ។ នៅក្នុងតំណាក់កាលស៊ើបសួរសហចៅក្រមស៊ើបអង្កេត និង មន្ត្រីដទៃទៀតដែលកំពុងបំពេញមុខងាររបស់សហចៅក្រមស៊ើប-

---

[6] ដោយសារតែ "សិទ្ធិជាមូលដ្ឋានទទួលបានការជម្រះក្តីដោយតុលាការមួយដែលឯករាជ្យ និង អនាគតិ" ត្រូវបានចាត់ទុកថា ជា "ផ្នែកមួយដ៏សំខាន់" នៃការធានាចំពោះការជម្រះក្តីដោយយុត្តិធម៌ (សាលដីកាក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៧៧) តុលាការ ITCY បានយល់ឃើញថា វិធានច្បាប់របស់ខ្លួន"ត្រូវតែបានគេយល់អោយបានទូលំទូលាយ ដើម្បីអនុញ្ញាតិឱ្យគេលើកឡើងនូវទឡ្ហីករណ៏នៃអនាគតិ [...] ដែលជាមូលដ្ឋានសម្រាប់ការប្តឹងជំទាស់"សេចក្តីសម្រេច *Karemera* កថាខណ្ឌ ៧ ។

[7] [redacted] ។

[8] ព័ត៌មានបន្ថែមស្តីពីភារកិច្ចជាក់លាក់ដែលត្រូវបំពេញដោយអ្នកស៊ើបអង្កេត អាចរកបានតាមរយៈសេចក្តីពិពណ៌នាអំពីការងាររបស់អ្នកដែលកាន់តួនាទីជាអ្នកស៊ើបអង្កេតកម្រិត P-3 នៅការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ភារកិច្ចសម្រាប់តួនាទីនេះជាអាទិ៍: ក) អនុវត្តកាតព្វកិច្ចនានាដែលដាក់ដោយរដ្ឋអាជ្ញា, រដ្ឋអាជ្ញារង, ប្រធានការិយាល័យប្រតិបត្តិការ ឬ ប្រធានក្រុមស៊ើបអង្កេត, ខ) ចូលរួមនៅក្នុងរៀបចំផែនការប្រមូលព័ត៌មានសំងាត់ និង ស៊ើបអង្កេត មុនចាប់ផ្តើមដំណើរការកិច្ចស៊ើបអង្កេតណាមួយ, គ) អនុលោមតាមការណែនាំរបស់ប្រធានក្រុមស៊ើបអង្កេត ត្រូវដឹកនាំប្រតិបត្តិការស៊ើបអង្កេតដល់សមាជិកដទៃទៀតនៃក្រុមស៊ើបអង្កេត, ឃ) រៀបចំផែនការប្រមូលព័ត៌មានសំងាត់សមស្របសម្រាប់ករណី ដែលស្ថិតនៅក្រោមការស៊ើបអង្កេត និង ង) ជួយប្រធានអង្គភាពគាំទ្រកិច្ចប្រតិបត្តិការ និង អង្គភាពដទៃទៀត សម្រាប់កិច្ចស៊ើបអង្កេតបន្តរបស់ការិយាល័យរដ្ឋអាជ្ញា និង ច) ផ្តល់មគ្គុទ្ទេសក៏ដល់ប្រធានក្រុមស៊ើបអង្កេតទៅលើនីតិវិធីវិធី និង បច្ចេកទេសស៊ើបអង្កេតដែលត្រូវប្រើប្រាស់, ឆ) ប្រមូលព័ត៌មានចារកម្ម និង ភស្តុតាងទាក់ទងនឹងភារកិច្ច និង សកម្មភាព, ជ) ចូលរួមនៅក្នុងសកម្មភាពនៅមូលដ្ឋាន ដូចជាសម្ភាសន៏សាក្សី, ជនសង្ស័យ និង ជនរងគ្រោះ, ចុះបញ្ជីព័ត៌មាន និង ភស្តុតាង ។ ការពិពណ៌នាអំពីភារកិច្ចទាំងអស់នេះអាចរកបាននៅ: http://www.icc-cpi.int/jobs/vacancies/786.html.

អង្កេត ដូចជាអ្នកស៊ើបអង្កេត Stephen Heder ត្រូវទទួលខុសត្រូវចំពោះកិច្ចស៊ើបសួរទាំងស្រុង រួមទាំងការស្រាវជ្រាវរកភស្តុតាងដោះបន្ទុកផងដែរ ។ ប្រសិនបើអ្នកស៊ើបអង្កេតណាមួយគ្មានឯករាជ្យ ឬ អនាគតិ វានឹងធ្វើអោយខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិច្ចស៊ើបសួរទាំងមូល ក៏ដូចជាសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌របស់លោក **អៀង សារី** ផងដែរ ។

4. អ្នកស៊ើបអង្កេត Stephen Heder កាលពីមុនត្រូវបានការិយាល័យសហព្រះរាជអាជ្ញាជ្រើសរើសឲ្យបំពេញការងារ មុនផ្លាស់ទៅកាន់ ក.ស.ច.ស[9]។ ទោះបីជាអ្នកស៊ើបអង្កេត Stephen Heder បានលាលែងចេញពីមុខតំណែងរបស់គាត់នៅ ក.ស.ច.ស នាពេលថ្មីៗនេះក៏ដោយ ក៏គេជឿរជាក់ថា គាត់នៅតែត្រូវបានជួលឲ្យបំពេញការងារជាទីប្រឹក្សា (Consultant) ឲ្យការិយាល័យនេះដដែល តាមរយៈការផ្តល់ជំនួយការ និងយោបល់ផ្សេងៗ។ អាស្រ័យហេតុនេះ ការខ្វះនូវអនាគតិរបស់គាត់អាចបន្តធ្វើឲ្យប៉ះពាល់ដល់កិច្ចស៊ើបសួរជាមិនខាន។ សូម្បីតែ អ្នកស៊ើបអង្កេត Stephen Heder បានបញ្ចប់ការងាររបស់គាត់ជាមួយ ក.ស.ច.ស ទៅហើយក្តី ក៏ការចូលរួមពាក់ព័ន្ធដ៏ធំធេងរបស់គាត់នៅក្នុងការប្រមូលចងក្រងព័ត៌មាន ដើម្បីរៀបរៀងតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឲ្យ ក.ស.ព និងនៅក្នុងកិច្ចស៊ើបសួរឲ្យ ក.ស.ច.ស នៅក្នុងសំណុំរឿងលេខ ០០១ និង ០០២ បានធ្វើអោយការអន្តរាយក៏បានកើតមានរួចជាស្រេចហើយដែរ។

5. ដើម្បីធ្វើការពិចារណាឲ្យបានពេញលេញ ថាតើមេធាវីការពារគួរស្នើសុំឲ្យមានការប្តឹងជំទាស់ដិតចិត្ត[10] ចំពោះអ្នកស៊ើបអង្កេត Stephen Heder និងថាតើសំណើសុំបន្ថែមទៀតចាំបាច់ត្រូវធ្វើឡើងដែរឬ

---

[9] សូមមើលសំណុំរឿងរបស់ អៀង សារី លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំព័ត៌មានស្តីពីទំនាស់ផលប្រយោជន៍សំខាន់ៗ ចុះថ្ងៃទី១០ ខែមករា ២០០៨។

[10] ចៅក្រមនឹងត្រូវបានគេពិចារណាថា ខ្វះឯករាជ្យភាព និងអនាគតិ ដែលនាំឲ្យមានការប្តឹងដិតចិត្ត ប្រសិនបើ "អនាគតិជាក់ស្តែងកើតមាន" (ហៅថា"ការធ្វើតេស្តតាមការយល់ដឹងផ្ទាល់ខ្លួនឬតេស្តសត្យានុម័ត" "Subjective Test") ឬ "ការលេចឡើងនូវភាពលំអៀងដែលមិនអាចទទួលយកបាន" (ហៅថា"ការធ្វើតេស្តតាមអង្គហេតុកាលៈទេសៈឬតេស្តអត្តនោម័ត" "Subjective Test")។ សូមមើលសាលដីកា Furundžija កថាខណ្ឌ ១៨៩។ សូមមើលរឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត, ICTR-98-44-T, "សេចក្តីសម្រេចទៅលើបណ្តឹងដិតចិត្តរបស់ Karemera ស្នើសុំឲ្យដកហូតចៅក្រមជំនុំជម្រះ" ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ (ហៅថា "សេចក្តីសម្រេច Karemera") កថាខណ្ឌ ៨។ រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត, SCSL-04-15-A, សេចក្តីសម្រេចទៅលើបណ្តឹងដិតចិត្តរបស់មេធាវីការពារក្តីស្នើសុំឲ្យដកហូតចៅក្រម Robertson ពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ " ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ (ហៅថា

យ៉ាងណា ដើម្បីជៀសវាងកុំឲ្យមានភាពអយុត្តិធម៌ជាក់ស្តែងនោះ មេធាវីការពារសូមស្នើដោយគោរពសុំព័ត៌មានទាំងឡាយដែលស្ថិតនៅក្នុងក្រោមគ្រប់គ្រងរបស់ ក.ស.ច.ស ទាក់ទងនឹង៖

ក. ការងារពីមុនៗរបស់អ្នកស៊ើបអង្កេត Stephen Heder ដែលជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ រួមទាំងតួនាទី និងសកម្មភាពពិតប្រាកដរបស់គាត់នៅក្នុងមុខតំណែងនេះ ក៏ដូចជាកិច្ចការផ្សេងទៀតដែលអាចពាក់ព័ន្ធទៅនឹងបញ្ហានៃសម្បទារបស់លោក Stephen Heder ដែលត្រូវមានភាពយុត្តិធម៌ និងអនាគតិក្នុងការបំពេញមុខងាររបស់គាត់ជាអ្នកស៊ើបអង្កេត និង

ខ. ថាតើការងារពីមុនដែលជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ ត្រូវបានលាតត្រដាងដែរឬទេជូនការិយាល័យសហព្រះរាជអាជ្ញា ដែលអ្នកស៊ើបអង្កេត Stephen Heder នេះបានបំរើការងារពីដើមដំបូង និងក្រោយមកបំរើការងារនៅ ក.ស.ច.ស នៅពេលដែលអ្នកស៊ើប-អង្កេត Stephen Heder ផ្ទេរភារកិច្ចមកកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ[11]។

---

"សេចក្តីសម្រេច Sesay") កថាខណ្ឌ៤។ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត, IT-02-60, សេចក្តីសម្រេចទៅលើពាក្យសុំរបស់ Blagojević អនុលោមតាម វិធាន ១៥(ខ)" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ៨។ អ្នកសង្កេតការណ៍ប្រកបដោយហេតុផលនោះគឺ "អ្នកដែលបានទទួលព័ត៌មាន ដោយមានការយល់ដឹងពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងទំនៀមទម្លាប់នៃសុច្ចរិតភាព និងអនាគតិ ដែលបង្កើតបានជាផ្នែកមួយនៃប្រវត្តិសាវតា និងការពិតដែលថាអនាគតិភាពគឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចជាច្រើន ដែលចៅក្រមទាំងឡាយសច្ចាថាគោរពតាម"។ សាលដីកា Furundžija កថាខណ្ឌ ១៩០។ (*quoting R.D.S. v. The Queen* (1997) Can. Sup. Ct., ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៧ កថាខណ្ឌ១១១។ សូមមើលផងដែរនូវរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង Brdjanin និង Talić, IT-99-36-T, "សេចក្តីសម្រេចទៅលើបណ្តឹងផិតចិត្តសុំដកហូតប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងសវនាការលើរឿងក្តី Brdjanin-Talić ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០២ កថាខណ្ឌ១៧ ។ SCSL បានបង្កើតការធ្វើតេស្តដូចខាងក្រោម "សំណួរដ៏សំខាន់ និងតឹងរ៉ឹងបំផុតនោះគឺថាតើអ្នកសង្កេតការណ៍ដែលឯករាជ្យត្រូវនិយាយ ឬមនុស្សប្រកបដោយហេតុផលម្នាក់ដោយយល់នូវសារទាំងនោះ នឹងមានមូលហេតុស្របច្បាប់ខ្លាចក្រែងថា [ចៅក្រម] ខ្វះអនាគតិ"។ សេចក្តីសម្រេច Sesay កថាខណ្ឌ១៥។

[11] ការតែងតាំងមុខងារ ដែលនាំឲ្យកើតមានហានិភ័យក្នុងការជះឥទ្ធិពលមិនត្រឹមត្រូវទៅលើលទ្ធផលនៃរឿងក្តី គឺមិនអាចអនុញ្ញាតបានឡើយ និងក្នុងករណីដែលមានការមន្ទិលសង្ស័យស្របច្បាប់កើតមានឡើង ដូចជា អព្យាក្រិត្យភាពរបស់ចៅក្រម ជាដើម ដែលគាត់ត្រូវតែដកខ្លួនចេញពីរឿងក្តីនេះ។ តាមការពិត ក្នុងការធ្វើការវាយតម្លៃ *ការពិតទាំងអស់ដែលត្រូវបានគេដឹងឮជាសាធារណៈ* គួរត្រូវបានយកមកពិចារណា, ការលេចឮគឺសំខាន់ណាស់ (សូមមើល Simor និង Emmerson § 6.119 - §6.124)។

00282717

ឯកសារ: A252

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

អាស្រ័យហេតុនេះ ដោយសារតែសារៈសំខាន់នៃបញ្ហាដែលបានលើកឡើងនៅក្នុងសំណើនេះ យើងខ្ញុំសូមទទូចស្នើសុំដោយក្តីគោរព ឲ្យចាត់ការលើសំណើនេះឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន និងសូមឲ្យផ្តល់ព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងអ្នកស៊ើបអង្កេត Stephen Heder ដើម្បីអោយមេធាវីការពារក្តី អាចពិចារណាថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌[12] តើត្រូវធ្វើស្នើសុំប្តឹងដិតចិត្តជាផ្លូវការចំពោះរូបគាត់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៣៤(៥) ឬយ៉ាងណា។

សូមលោកចៅក្រមមេត្តាទទួលនូវសំណើនេះដោយក្តីគោរព។

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

| អាង ឧត្តម | Michael KARNAVAS |
| --- | --- |

សហមេធាវីរបស់លោក **អៀង សារី**

ចុះហត្ថលេខានៅភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

[12] អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង "នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ [...] គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។" បន្ថែមលើនេះទៅទៀត មាត្រា ១២(២) នៃកិច្ចព្រមព្រៀងចែងថា អង្គជំនុំជម្រះនៃ អ.វ.ត.ក "ត្រូវអនុវត្តយុត្តិធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ហៅថា "ICCPR") ដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។ មាត្រា ១៤(១) នៃ ICCPR ដែលពាក់ព័ន្ធចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នា ចំពោះមុខតុលាការ និង សាលាជម្រះក្តី ។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ច ក្នុងវិស័យរដ្ឋប្បវេណី..........។ (គូសបញ្ជាក់បន្ថែម)